៦-តំណាង សាលាខេត្តកោះកុង (អាជ្ញាធរដែនដី) ជាសមាជិក

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ច ចុះដល់ទីកន្លែង ដើម្បីពិនិត្យ និងវាយតំលៃគុណភាពបច្ចេកទេសផ្លូវ ស្ពាន និង លូ ដែលបានធ្វើរួចហើយ និងផ្លូវដែលបានឈូសឆាយហើយ ព្រមទាំងវាយតំលៃឈើដែលកាន់កាប់រួចហើយ ដើម្បីធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

ប្រការ ៣ : គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រាផ្លូវការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីសំរួលការងារ ។

-មធ្យោបាយធ្វើដំណើរ និងចរិការចុះត្រួតពិនិត្យ ជាបន្ទុករបស់គកមីក្រសួងនីមួយៗ ។

-ប្រធានគណៈកម្មការត្រូវអញ្ជើញគ្រប់សមាជិកមកប្រជុំ ដើម្បីពិភាក្សាកំណត់ពេលវេលា និងចុះធ្វើការងារនេះ ។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអភិបាលខេត្តកោះកុង ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីស្តីទី

ហត្ថលេខា និងត្រា

ស ខេង

***

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៩

## សេចក្តីសំរេចលេខ ៦៤ សសរ

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង
## ដើម្បីចុះពិនិត្យវាយតំលៃលើផលប៉ះពាល់ដល់សំណង់ ផ្ទះសំបែង
## ដីធ្លីប្រជារាស្ត្រនៅតាមកំណាត់ផ្លូវ ជាតិលេខ៣ និង លេខ៦

* * *

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សម្រេច**

ប្រការ ១ : បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីធ្វើការវាយតម្លៃលើការប៉ះពាល់ដល់សំណង់ ផ្ទះសំបែង ដីធ្លី ប្រជារាស្ត្រ ក្នុងគម្រោងស្តារឡើងវិញផ្លូវជាតិ តាមកំណាត់ផ្លូវជាតិលេខ៣ និងលេខ៦ ។

ប្រការ ២ : គណៈកម្មការអន្តរក្រសួងនេះមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១-តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២-តំណាង ក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៣-តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤-តំណាង ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៥-តំណាង ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៦-អភិបាលខេត្ត-ក្រុង ដែលពាក់ព័ន្ធនឹងគំរោង | សមាជិក |
| -សៀមរាប | |
| -កំពង់សោម | សមាជិក |

ប្រការ ៣ : គណៈកម្មការអន្តរក្រសួង មានភារកិច្ចចុះទៅពិនិត្យផ្ទាល់ទីកន្លែង ធ្វើស្ថិតិលើការប៉ះពាល់ដល់ សំណង់ ផ្ទះសំបែង ដីធ្លីប្រជារាស្ត្រដែលស្ថិតនៅតាមកំណាត់ផ្លូវជាតិលេខ៣ និងលេខ៦ រួចធ្វើការវាយតម្លៃ អោយបានសមស្រប ដើម្បីមានមូលដ្ឋានដាក់ជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេចនូវថវិកាមួយចំនួន ជា សោហ៊ុយលើការទូទាត់ជូនដល់ប្រជារាស្ត្រវិញ ។

ប្រការ ៤ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ អភិបាល អភិបាលរង ខេត្ត-ក្រុង ដែលពាក់ព័ន្ធនឹងគំរោង សៀមរាប កំពង់សោម និងមន្ត្រីពាក់ព័ន្ធ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រីស្តីទី

ហត្ថលេខា និងត្រា

ស ខេង

***